# រឿងមហាល្លកចណ្ឌាលី

( ចាក វិ. ខុ. )

( ការចំរើននូវពុទ្ធគុណ មានតម្លៃកាត់មិនបាន )

ថ្ងៃ មួយព្រះសម្ពុទ្ធបរមគ្រូ ទ្រង់ស្ថិតនៅជាសុខក្នុងនិរោធសាមាបត្តិ នាក្រុងរាជគ្រឹះ ។ ក្នុងពេលជិតភ្លឺ ព្រះអង្គទ្រង់ប្រមើលនិស្ស័យរបស់សត្វលោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញស្រីចណ្ឌាលចាស់ម្នាក់ នៅក្នុងចណ្ឌាលគ្រាម នាក្រុងរាជគ្រឹះនោះ ជាស្ត្រីល្ងង់អាប់ឥតប្រាជ្ញា តាំងតែពីកើតមកដរាបដល់ចាស់ជរា ពុំដែលបានធ្វើកុសលណាមួយឡើយ ប្រព្រឹត្តធ្វើតែអំពើទុច្ចរិតម្យ៉ាង កាលបើស្លាប់ នឹងធ្លាក់ទៅកើតក្នុងមហានរកពុំខានលុះទ្រង់ជ្រាបដូច្នេះហើយ ក៏មានព្រះទ័យករុណាចំពោះយាយចណ្ឌាលនោះពន់ពេក ដល់ ភ្លឺច្បាស់ឡើង ក៏ទ្រង់បាត្រចីវរនាំភិក្ខុសង្ឃជាច្រើនអង្គមានព្រះមោគ្គល្លានជា ដើមចរចូលទៅបិណ្ឌបាតក្នុងចណ្ឌាលគ្រាមនោះ ។

យាយចណ្ឌាល កំពុងតែដើរទប់ខ្លួនតាមមាគ៌ា ព្រះ ភគវាទ្រង់ឈរវាំងផ្លូវពុំឱ្យយាយចណ្ឌាលនោះដើរទៅទីដ៏ទៃបានឡើយ ។ ព្រះមោគ្គល្លានបានជ្រាបហេតុនោះហើយ ក៏ប្រាប់យាយចណ្ឌាលថា នែ ! យាយព្រឹទ្ធា យាយអញ្ជើញទៅណា ? ចូរថ្វាយបង្គំព្រះសម្ពុទ្ធជាបរមគ្រូសិន ការដែលបាន ជួបនឹងព្រះបរមគ្រូនេះ ប្រសើរពេកណាស់ ព្រោះព្រះអង្គជាព្រះអរហន្តដ៏ ប្រសើរ ទ្រង់ត្រាស់ដឹងសព្វដោយព្រះអង្គឯង ឥតមានគ្រូអាចារ្យណាប្រដៅដាស់តឿនព្រះអង្គឡើយ ព្រះអង្គមានព្រះទ័យករុណាអាណិតដល់យាយ ទើបទ្រង់និមន្តមកដើម្បីឱ្យយាយបានសេចក្ដីសុខចំរើន ទៅកើតក្នុងស្ថានសួគ៌ ចូរ យាយត្រេកអរចំពោះព្រះសម្ពុទ្ធបរមគ្រូចុះ ។ យាយចណ្ឌាលលើកដៃឡើងបាំងថ្ងាស់ អើតមើលព្រះភ័ក្ត្រព្រះសម្ពុទ្ធ សេចក្ដីជ្រះថ្លាកើតឡើង ក៏អង្គុយដាក់ឈើច្រត់ក្បែរខ្លួនហើយថ្វាយបង្គំដោយសេចក្ដីជ្រះថ្លា មានពុទ្ធានុស្សតិជាអារម្មណ៍ ។ ព្រះសម្ពុទ្ធទ្រង់ជ្រាបថា យាយចណ្ឌាលនេះអស់ អាយុ ហើយ ត្រូវស្លាប់ក្នុងពេលឥឡូវនេះ កាលបើស្លាប់ហើយនឹងបានទៅកើតក្នុងស្ថានតាវតឹង្សពុំខាន លុះ ជ្រាបដូច្នេះហើយ ក៏និមន្តហួសទៅបិណ្ឌបាតក្នុងចណ្ឌាលគ្រាមនោះទៅ ។ ឯយាយចណ្ឌាលក៏ក្រោកដើរទៅផ្ទះមានចិត្តស្ថិតនៅក្នុងពុទ្ធគុណជាឯកគ្គតារម្មណ៍ ។ ក្នុងពេលនោះ មានមេគោមួយមានកូនខ្ចី បានឃើញព្រះសម្ពុទ្ធនិងព្រះសង្ឃក៏

ផ្អើលស្ទុះទៅជាន់យាយចណ្ឌាល នោះស្លាប់ទៅ ។ យាយចណ្ឌាលក៏ទៅកើតក្នុង វិមានមាសកំពស់ ១២ យោជន៍ នាស្ថានតាវតឹង្សទេវលោក សោយទិព្វ សម្បត្តិជាសុខក្សេមក្សាន្ត ។

សូមអស់លោកអ្នកអនុមោទនា !

ចប់